## ការិយាល័យឧត្តមស្នងការ អង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស នៅកម្ពុជា និងសកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា

## *បទបង្ហាញស្តីពី*

## *“បញ្ហាប្រឈមនានាក្នុងការការពារក្តីក្នុងសំណុំរឿងឧក្រិដ្ឋកម្មធ្ងន់ធ្ងរ”*

វាគ្មិន៖ លោកមេធាវី អាង ឧត្តម សហមេធាវីជាតិ និងចូលរួមដោយសហការីរបស់
លោកគឺលោក **Michael KARNAVAS** ដែលជាសហមេធាវីអន្តរជាតិ
នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក)

*បាឋកថាមានរយៈពេល៣០នាទី ជាភាសាខ្មែរ បន្ទាប់មកផ្តល់ឱកាសសម្រាប់សំណួរ និងចម្លើយ*
*អមដោយការបកប្រែជាភាសាអង់គ្លេស*

កាលបរិច្ឆេទ និងម៉ោង៖ ថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១១ ចាប់ពីម៉ោង៣.៣០-៥.០០-ល្ងាច
ទីកន្លែង៖ នៅសាលសន្និសិទស្រីឱមនៃសកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា
(លេខ១៨៤ មហាវិថីនរោត្តម)

រៀបចំទទួលដោយមហាវិទ្យាល័យនីតិសាស្ត្រ និងកិច្ចការសាធារណៈ
និងគ្លិនិកច្បាប់នៃសកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា



លោកមេធាវី អាង ឧត្តម ធ្លាប់បានបំរើការងារជាមេធាវីការពារក្តីព្រហ្មទណ្ឌជាមួយអង្គការក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា និងអង្គការជំនួយផ្នែកច្បាប់នៅកម្ពុជា។ លោកបានបង្កើតក្លឹប មេធាវីឯកជនផ្ទាល់របស់លោកចាប់តាំងពីឆ្នាំ១៩៩៩ ហើយលោកមានមុខតំណែងជាប្រធានអង្គភាពច្បាប់នៅ មជ្ឈមណ្ឌល អភិវឌ្ឍន៍សង្គមពីឆ្នាំ២០០៦។ លោកគឺជា សមាជិកគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជាចាប់តាំងពីឆ្នាំ១៩៩៧។ បច្ចុប្បន្ននេះ លោកកំពុងតែបំរើការងារជាសហមេធាវីជាតិនៅអង្គភាព គាំពារការការពារក្តីក្នុងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។

បើកចំហសម្រាប់សាធារណជនទាំងអស់! សូមស្វាគមគ្រប់មជ្ឈដ្ឋានទាំងអស់ចូលរួមក្នុងឈុតបឋកថានេះ!

***អំពីឈុតបាឋកថាកេរ្តិ៍ដំណែលសិទ្ធិមនុស្ស និងយុត្តិធម៌អន្តរជាតិ៖*** ឈុតបាឋកថាកេរ្តិ៍ដំណែលសិទ្ធិមនុស្ស និងយុត្តិធម៌អន្តរជាតិគឺជាឈុតបាឋកថា ដែលសហការរៀបចំដោយការិយាល័យឧត្តមស្នងការ អង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា និងសកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា។ គោលបំណងនៃឈុតបាឋកថានេះគឺដើម្បីទទួលយកជំនាញពីមន្ត្រី ដែលបំរើការងារនៅអ.វ.ត.ក ដើម្បីលើកកម្ពស់កិច្ចពិភាក្សារបស់សាធារណជនឲ្យបានទូលំទូលាយថែមទៀតអំពីបញ្ហាសិទ្ធិមនុស្ស និងយុត្តិធម៌អន្តរជាតិតាមសហសម័យ។ ឈុតបាឋកថាលើកទី១ត្រូវបានធ្វើឡើងដោយលោក Andrew Cayley សហព្រះរាជអាជ្ញាអន្តរជាតិ កាលពីថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១១ ហើយឈុតបាឋកថាលើកទី២ត្រូវបានធ្វើឡើងដោយលោក ជំទាវ ជា លាង សហព្រះរាជអាជ្ញាជាតិ កាលពីថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១១ និងឈុតបាឋកថាលើកទី៣ត្រូវបានធ្វើ ដោយលោកស្រីចៅក្រម Silvia Cartwright កាលពីថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១១។ ចំណុចសំខាន់ៗពីឈុតបាឋកថាទាំងនេះនឹងត្រូវផ្សព្វផ្សាយជាសាធារណៈ បន្ទាប់ពីឈុតបាឋកថាទាំងនេះត្រូវបានបញ្ចប់។